Alameda County
Social Services Agency

# Child Care Provider Grant Program (កម្មវិធីផ្តល់ថវិកាសម្រាប់អ្នកផ្តល់សេវាថែទាំកុមារ) នៅក្នុងខោនធី Alameda បើកឡើងវិញហើយ៖ តើត្រូវដឹងអ្វីខ្លះ

**ដំណឹងដ៏រំភើប!** Alameda County Board of Supervisors (BOS) (គណៈគ្រប់គ្រងនៃខោនធី Alameda) និង Alameda County Social Services Agency (SSA) (ទីភ្នាក់ងារសេវាសង្គមកិច្ចនៃខោនធី Alameda) នឹងផ្តល់ឱកាសថ្មីមួយសម្រាប់ផ្តល់ថវិកាគ្មានកំហិត ដើម្បីផ្តល់ការឧបត្ថម្ភដល់ការងារដ៏សំខាន់របស់អ្នកផ្តល់សេវាថែទាំកុមារដែលមានអាជ្ញាប័ណ្ណ នៅក្នុងខោនធី Alameda។



ឱកាសផ្តល់ថវិកានេះកើតឡើង បន្ទាប់ពីជុំដំបូងនៃការផ្តល់ថវិកាមួយដងទៅឲ្យកម្មវិធី Family Child Care (FCC) និងកម្មវិធី Center-based programs តូច និងធំ ចំនួនជាង 1,200 កម្មវិធី ដែលមានអាជ្ញាប័ណ្ណ និងមានលក្ខណៈសម្បត្តិ នៅក្នុងខោនធី Alameda ក្នុងទឹកប្រាក់សរុប $3.74 លាន ដែលបានដាក់ពាក្យសុំថវិកា ក្នុងចន្លោះខែមិថុនា ឆ្នាំ 2022 និងខែមីនា ឆ្នាំ 2023។ ខោនធី Alameda បានទទួលថវិកា ដោយប្រើមូលនិធិនៃច្បាប់ American Rescue Plan Act (ARPA) ដើម្បីផ្តល់ការឧបត្ថម្ភដល់តួនាទីដ៏សំខាន់របស់អាជីវកម្មថែទាំកុមារ ក្នុងអំឡុងវិបត្តិជំងឺកូវីដ-19 ឆ្លងរាលដាលជាសាកល។  BOS បានអនុម័តលៃទុកប្រាក់បន្ថែមចំនួន $5.9 លាន (+$1.3 លាន ដែលជាទឹកប្រាក់នៅសល់ពីមូលនិធិដំបូង) នៅក្នុងទឹកប្រាក់សរុបចំនួន $7.2 លាន ជាថវិកាសម្រាប់ការថែទាំកុមារ ដែលផ្តល់លទ្ធភាពឲ្យ SSA បើកផតថលថវិកានេះឡើងវិញ។

## *ឱកាសថ្មីនៃកម្មវិធីផ្តល់ថវិកា៖ ព័ត៌មានលម្អិតសំខាន់ៗ៖*

- **គោលបំណងនៃថវិកា៖ ថវិកានេះ គឺដើម្បីពង្រឹងលទ្ធភាពទទួលបានការថែទាំកុមារ តម្លៃថោកល្មម និងស្ថិរភាព បន្ទាប់ពីវិបត្តិជំងឺកូវីដ-19 ឆ្លងរាលដាលជាសាកល។**

- **រយៈពេលផ្តល់ថវិកា៖** ឱកាសផ្តល់ថវិកាបើកនៅថ្ងៃទី 1 ខែឧសភា ឆ្នាំ 2024 និងបិទនៅថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2024។
- **លក្ខណៈវិនិច្ឆ័យលើលក្ខណៈសម្បត្តិ៖**
    - *កម្មវិធី Family Child Care (FCC) និងកម្មវិធី Center-based programs តូច និងធំ នៅក្នុងខោនធី Alameda ដែលមានអាជ្ញាប័ណ្ណបច្ចុប្បន្ន ដែលបានធ្វើប្រតិបត្តិការ នៅមុនខែមិថុនា ឆ្នាំ 2021 និងដែលបន្តមានអាជ្ញាប័ណ្ណ Community Care Licensing មានលក្ខណៈសម្បត្តិទទួលបានថវិកា។*

- **ចំនួនថវិកា៖** ថវិកាមានចាប់ពី $4,200 សម្រាប់កម្មវិធី FCCs និងកម្មវិធី Center-based programs ធំ ដល់ $3,200 សម្រាប់កម្មវិធី FCCs តូច។
- **របៀបទទួលបានថវិកា៖**
    - **ប្រសិនបើអ្នកគឺជាអ្នកផ្តល់សេវាថែទាំកុមារ ដែលមានអាជ្ញាប័ណ្ណពីរដ្ឋ ហើយបានទទួលថវិកាលើកដំបូងក្នុងចន្លោះខែមិថុនា ឆ្នាំ 2022 - ខែមីនា ឆ្នាំ 2023** មិនចាំបាច់ត្រូវធ្វើសកម្មភាពបន្ថែមទៀតឡើយ។ ព័ត៌មានរបស់អ្នកបន្តស្ថិតនៅក្នុងសំណុំឯកសារហើយយើងបានផ្ទៀងផ្ទាត់បញ្ជាក់ជាមួយ California Department of Social Services (CDSS) ថា អ្នកបន្តធ្វើជាអ្នកផ្តល់សេវាដែលមានអាជ្ញាប័ណ្ណពីរដ្ឋនាពេលបច្ចុប្បន្ន។ យើងនឹងផ្ញើថវិកាជាសែកទៅឲ្យអ្នកដោយស្វ័យប្រវត្តិនៅត្រឹមថ្ងៃទី 15 ខែមិថុនា ឆ្នាំ 2024។
- 
    - .**ប្រសិនបើអ្នកមិនបានស្នើសុំថវិកាលើកដំបូងទេ អ្នកនៅតែមានលក្ខណៈ***សម្បត្តិ ដើម្បីដាក់ពាក្យសុំ និងទទួលបានថវិកាលើកដំបូងចំនួន $3,350 សម្រាប់កម្មវិធី FCCs និងកម្មវិធី Center-based programs ធំ និងចំនួន $2,350 សម្រាប់កម្មវិធី FCCs តូច បន្ថែមពីលើថវិកាលើកទីពីរចំនួន $4,200 សម្រាប់កម្មវិធី FCCs និង Center-based programs ធំ និងចំនួន $3,200 សម្រាប់កម្មវិធី FCCs តូច។ ដើម្បីទទួលបានថវិកា អ្នកត្រូវតែ៖*

    - *បំពេញទម្រង់ពាក្យចុះឈ្មោះអនឡាញនៅត្រង់នេះ និងដាក់ទម្រង់ Form W-9 មក។*

*ថវិកានឹងផ្ញើចេញតាមប្រៃសណីយ៍ ក្រោយពីបានទទួល និងបញ្ជាក់ពីសុពលភាពនៃពាក្យសុំ។ សូមទុកពេល 8 សប្តាហ៍សម្រាប់ទទួលថវិកា។*

*ក្រោយពីអ្នកទទួលបានថវិកា យើងចង់បានដំណឹងពីអ្នក! សូមផ្ញើសក្ខីកម្មរបស់អ្នកមកឲ្យយើងនៅត្រង់នេះ។*

**ព័ត៌មានទំនាក់ទំនង៖**
*ចំពោះសំណួរ សូមទាក់ទងមក* Alameda County Social Services Agency, Office of Policy, Strategy, and Innovation *តាម* SSAChildCareGrant@acgov.org.

© 2024, Alameda County Social Services Agency